# លក្ខខណ្ឌការងារ
# សម្រាប់អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC)

## ១. សេចក្តីផ្តើម

គម្រោង "សន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា (SRELFOOD Project 2)" ដែលទទួលថវិកាគាំទ្រពីរាជរដ្ឋាភិបាលប្រទេសជប៉ុន តាមរយៈកម្មវិធីស្បៀងអាហារពិភពលោក (WFP) ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់នៃទឹកជំនន់ទៅលើសន្តិសុខស្បៀងរបស់គ្រួសារ និងសមហគមន៍ដែលរងផលប៉ះពាល់ដោយសារទឹកជំនន់ តាមរយៈផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលខេត្ត រដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំគោលដៅអំពីការបញ្ជ្រាបការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ឬផែនការយុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីបីឆ្នាំរំកិលរបស់ឃុំ ព្រមទាំងគាំទ្រដល់រដ្ឋបាលឃុំគោលដៅក្នុងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅឃុំគោលដៅចំនួន១៦ ស្រុកគោលដៅចំនួន០៨ នៃខេត្តគោលដៅចំនួន០៤ គឺខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តកំពង់ធំ។

គម្រោងនឹងផ្តល់ថវិកាគាំទ្រគម្រោងមូលនិធិឃុំ ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពជាអាទិភាពរបស់ឃុំដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ (CDP) និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ (CIP) និងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ ថវិកាដែលគាំទ្រពីគម្រោងនឹងធ្វើការវិភាជប្រមាណ ៨៨% សម្រាប់ការវិនិយោគទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងចំនួនអតិបរិមា១២%នៃថវិកាត្រូវប្រើប្រាស់សម្រាប់ជួលអ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) ដើម្បីជួយក្រុមប្រឹក្សាឃុំក្នុងការសិក្សាបច្ចេកទេស ការរៀបចំគំនូសប្លង់ ការគណនាតម្លៃប៉ាន់ស្មាន ការរៀបចំគ្រោងការគម្រោង កិច្ចលទ្ធកម្ម ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យការងារសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំឆ្នាំ២០២២ ដែលបច្ចុប្បន្នសេវាបច្ចេកទេសត្រូវបានគាំទ្រដោយមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធមកពីទីចាត់ការផែនការនិងវិនិយោគខេត្ត និងមន្ត្រីទទួលបច្ចេកទេសគាំទ្រឃុំ និងអនុវត្តតាមគោលការណ៍នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ (PIM) និងសៀវភៅបច្ចេកទេសគម្រោងហេដ្ឋារចនាសម្ព័ន្ធ គ.ជ.អ.ប.។

ដើម្បីធានាគុណភាពនៃការផ្តល់សេវាបច្ចេកទេសក្នុងការគាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ គម្រោង SRELFOOD Project 2 នៃលេខាធិកាដ្ឋាន គ.ជ.អ.ប. នឹងប្រើប្រាស់ថវិកាមួយចំនួនសម្រាប់ជ្រើសរើស TSC ដើម្បីជួយក្រុមប្រឹក្សាឃុំគោលដៅទាំង១៦ឃុំ នៃខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តកំពង់ធំ ក្នុងការសិក្សាបច្ចេកទេស រៀបចំគំនូសប្លង់បច្ចេកទេស គណនាតម្លៃប៉ាន់ស្មាន កិច្ចលទ្ធកម្ម និងការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យការសាងសង់គម្រោងវិនិយោគរបស់ឃុំ សម្រាប់ជំនួសឱ្យអ្នកជំនួយការបច្ចេកទេសដែលកំពុងជួយឃុំនាពេលកន្លងមក។

## ២. គោលបំណងនៃការផ្តល់សេវាបច្ចេកទេស

គោលបំណងនៃសេវាបច្ចេកទេស[1] គឺជាការផ្តល់ឱ្យក្រុមប្រឹក្សាឃុំនូវសេវាបច្ចេកទេសប្រកបដោយគុណភាពសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ តម្រូវការផ្តល់សេវាបច្ចេកទេសនេះ រួមទាំង**ការប្រមូលទិន្នន័យ ព័ត៌មាននៅមូលដ្ឋាន ការសិក្សាលទ្ធភាពគម្រោង ការរៀបចំគ្រោងការគម្រោង ការប៉ាន់ស្មានតម្លៃគម្រោង ការរៀបចំឯកសារព័ត៌មានគម្រោង ឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យាអនុវត្តគម្រោង ការគាំទ្រដំណើរការដេញថ្លៃ និងការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា**។ល។ គម្រោងនឹងត្រូវសាងសង់ដោយអ្នកទទួលការ (អ្នកម៉ៅការ) និងចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាឃុំ តាមដានការអនុវត្តកិច្ចសន្យាគម្រោងដោយគណៈកម្មការគ្រប់គ្រងគម្រោងឃុំ និងអ្នកផ្តល់សេវាបច្ចេកទេសឯកជន តាមរយៈការគាំទ្រហិរញ្ញវត្ថុដោយគាំទ្រថវិកាដោយគម្រោង "សន្តិសុខស្បៀង និងការគាំទ្រការស្តារឡើងវិញរបស់សហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់ដោយសារទឹកជំនន់នៅប្រទេសកម្ពុជា (SRELFOOD Project 2)"។

## ៣. ទីតាំង រយៈពេល និងពេលវេលានៃការផ្តល់សេវាបច្ចេកទេស

អ្នកផ្តល់សេវាបច្ចេកទេសឯកជន នឹងត្រូវជ្រើសរើសតាមរយៈកិច្ចសន្យាដាច់ពីគ្នានៅតាមខេត្តគោលដៅនីមួយៗ ដើម្បីផ្តល់សេវាបច្ចេកទេសរហូតចប់ការអនុវត្តគម្រោង។ កិច្ចសន្យាផ្តល់សេវាបច្ចេកទេស និងបន្ទុកការងារមានសង្ខេបនៅក្នុងតារាងដូចខាងក្រោម៖

| ល.រ | ស្រុកគោលដៅ | ឃុំគោលដៅ | ឈ្មោះគម្រោង | ចំនួនគម្រោង |
|---|---|---|---|---|
| **១. ខេត្តកំពង់ឆ្នាំង** | | | | |
| ១ | បរិបូរណ៍ | ខុនរ៉ង | 1. ជួសជុលផ្លូវក្រាលក្រួសក្រហម | ០២គម្រោង |
| ២ | ជលគិរី | ព្រៃគ្រី | 2. ជួសជុលផ្លូវថ្មភ្នំចំនួន២ខ្សែ | |
| **២. ខេត្តពោធិ៍សាត់** | | | | |
| ១ | បាកាន | អូរតាប៉ោង | 3. ស្ពារប្រឡាយ | ០៥គម្រោង |
| | | | 4. ស្ពារប្រឡាយ | |
| | | បឹងបត់កណ្តាល | 5. ស្ពារប្រឡាយ | |
| | | | 6. ស្ពារអាងស្តុកទឹក១កន្លែង | |
| | | ស្នាមព្រះ | 7. ស្ពារបឹងធម្មជាតិ១កន្លែង | |
| ២ | កណ្តៀង | ស្រែស្តុក | 8. សាងសង់ផ្លូវក្រាលក្រួសក្រហម2ខ្សែ | ០៤គម្រោង |
| | | កញ្ជរ | 9. សាងសង់ផ្លូវក្រាលក្រួសក្រហម2 | |
| | | អន្លង់វិល | 10. ស្ពារប្រលាយ | |
| | | | 11. ជួសជុលផ្លូវក្រាលក្រួសក្រហម | |
| **៣. ខេត្តបាត់ដំបង** | | | | |

[1] ដូចបានពិពណ៌នាក្នុងសៀវភៅ ភីម ការផ្តល់សេវាទាំងនេះរួមបញ្ចូលទាំងការពិនិត្យមើលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ប៉ុន្តែការពិនិត្យមើលផ្នែកនេះមិនបានដាក់បញ្ចូលទៅក្នុងការងារផ្តល់សេវាបច្ចេកទេសឯកជននេះទេ។

| ល.រ | ស្រុកគោលដៅ | ឃុំគោលដៅ | ឈ្មោះគម្រោង | ចំនួនគម្រោង |
|---|---|---|---|---|
| ១ | ស្រុកថ្មគោល | បឹងព្រីង | 12. ស្ពានប្រឡាយ | ០៥គម្រោង |
| | | តាម៉ឺន | 13. ជួសជុលផ្លូវក្រាលក្រួសក្រហម | |
| | | | 14. ស្ពានប្រឡាយ | |
| | | អូរតាគី | 15. ជួសជុលផ្លូវក្រាលក្រួសក្រហម | |
| | | | 16. ស្ពានប្រឡាយ | |
| ២ | ស្រុកមោងឫស្សី | កកោះ | 17. ស្ពានប្រឡាយប្រ | ០៦គម្រោង |
| | | | 18. ស្ពានប្រឡាយ | |
| | | ជ្រៃ | 19. ជួសជុលផ្លូវក្រាលក្រួសក្រហម | |
| | | | 20. ស្ពានប្រឡាយ និងទ្វារទឹក | |
| | | ឫស្សីក្រាំង | 21. ជួសជុលផ្លូវក្រាលក្រួសក្រហម | |
| | | | 22. ស្ពានប្រឡាយ | |
| **៤. ខេត្តកំពង់ធំ** | | | | |
| ១ | កំពង់ស្វាយ | កំពង់គោ | 23. ជួសជុលផ្លូវក្រាលក្រួសក្រហម | ០៣គម្រោង |
| ២ | ប្រាសាទសំបូរ | សំបូរណ៍ | 24. ជីកប្រឡាយ | |
| | | | 25. ជួសជុលផ្លូវក្រាលក្រួសក្រហម | |

## ៤. វិសាលភាពនៃការផ្តល់សេវា

សេវាកម្មបច្ចេកទេសត្រូវបានផ្តល់ក្នុងបរិបទនៃក្របខ័ណ្ឌការងារវិមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្រោមកិច្ចព្រមព្រៀងថវិកាដោយកម្មវិធីស្បៀងអាហារពិភពលោក។ ហេតុនេះ សេវាកម្មទាំងនោះនឹងត្រូវធ្វើការជាមួយក្រុមប្រឹក្សាឃុំអ្នកទទួលការសាងសង់ (អ្នកម៉ៅការ) និងមានទាំងការងារទំនាក់ទំនងជាមួយបុគ្គលិករដ្ឋាភិបាលថ្នាក់ខេត្ត និងថ្នាក់ស្រុក ដើម្បីប្រាកដថាការសិក្សាគ្រោងការគម្រោងទាំងនោះបានពិនិត្យ និងបញ្ជាក់យ៉ាងត្រឹមត្រូវដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ទីចាត់ការផែនការ និងវិនិយោគខេត្ត(PID) និងក្រុមប្រឹក្សាឃុំ។ អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) នឹងត្រូវធ្វើការនៅតាមឃុំគោលដៅរបស់ខ្លួន និងស្ថិតនៅក្រោមការសម្របសម្រួលត្រួតពិនិត្យមើលពីមន្ត្រីគាំទ្របច្ចេកទេសរបស់គម្រោង។ អ្នកផ្តល់សេវាបច្ចេកទេសឯកជននឹងត្រូវធានាការរៀបចំ និងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឃុំគោលដៅដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន (TSC) បានអនុវត្តយ៉ាងហ្មត់ចត់តាមសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ (PIM) និងសៀវភៅណែនាំបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធ គ.ជ.អ.ប.។

**ការទទួលខុសត្រូវជាក់លាក់របស់អ្នកអ្នកផ្តល់សេវាបច្ចេកទេសឯកជនមានដូចតទៅ៖**

ក) បញ្ជាក់ជាមួយក្រុមប្រឹក្សាឃុំថាគម្រោងដែលត្រូវគ្រោងរៀបចំមានក្នុងបញ្ជីគម្រោងអាទិភាព ទីតាំងគម្រោងច្បាស់លាស់ មិនមានផលប៉ះពាល់ដីធ្លីកម្មសិទ្ធិឯកជនឡើយ និងមិនស្ថិតក្នុងផែនការសាងសង់ឬជួលជុលរបស់មន្ទីរជំនាញពាក់ព័ន្ធនានា។ នៅពេលទទួលបានការបញ្ជាក់ជាលាយល័ក្ខអក្សរពីក្រុមប្រឹក្សាឃុំរួចហើយ ទំហំការងារត្រូវបានកំណត់សម្រាប់ដំណាក់កាលសិក្សាឋានលេខា ការប្រមូលព័ត៌មានបច្ចេកទេស គម្រោងដែលត្រូវគ្រោង និងការរៀបចំសំណើគម្រោងពេញលេញ។

ខ) រៀបចំឯកសារដេញថ្លៃ ដូចជាការគ្រោងប្លង់បច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងប៉ាន់ស្មានតម្លៃគម្រោង រួចផ្ញើជូនមេឃុំពិនិត្យដើម្បីសម្រេច និងអនុម័ត

គ) ជួយឃុំក្នុងការរៀបចំឯកសារដេញថ្លៃ និងពិនិត្យបញ្ជាក់បច្ចេកទេស

ឃ) ត្រួតពិនិត្យ និងជួយរៀបចំឯកសារដេញថ្លៃ សម្របសម្រួលដំណើរការដេញថ្លៃ និងជួយឃុំរៀបចំឯកសារកិច្ចសន្យារវាងឃុំ និងអ្នកទទួលការសាងសង់

ង) តាមដាន និងត្រួតពិនិត្យការងារសាងសង់ដោយអ្នកទទួលការសាងសង់ក្នុងរយៈពេលសាងសង់ ជួយគណៈកម្មការគ្រប់គ្រងគម្រោងឃុំអំពីការតាមដាន ត្រួតពិនិត្យ ការវាយតម្លៃគម្រោង និងផ្តល់អនុលោមភាពលើរបាយការណ៍រីកចម្រើនដាក់ជូនក្រុមប្រឹក្សាឃុំ និង

ច) ផ្ទេរប្រគល់ការងារទៅឱ្យមន្ត្រីគាំទ្របច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តមកពីទីចាត់ការផែនការ និងវិនិយោគនៅពេលបញ្ចប់ការងារសាងសង់

ឆ) កាតព្វកិច្ចបង់ពន្ធ គឺជាបន្ទុករបស់អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC)។

កិច្ចការរបស់អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) នឹងមិនមានលក្ខណៈបន្តជាអចិន្ត្រៃយ៍ឡើយ ព្រោះការបំពេញរាល់លក្ខខណ្ឌ និងការឯកភាពផ្តល់កិច្ចសន្យាមិនមែនជាផ្នែកមួយនៃវិសាលភាពការងារឡើយ។ ទោះជាយ៉ាងណាក្តី ដោយហេតុថាគម្រោងមូលនិធិអភិវឌ្ឍន៍ឃុំនៅក្នុងស្រុក[2] ត្រូវបានបញ្ចូលទៅក្នុងកិច្ចសន្យាមួយក្នុងការផ្តល់សេវាអាចត្រូវបានអនុវត្តជាបន្តបន្ទាប់ និងអាចបន្តស្ទើរតែជាប្រចាំ។ ការងារទាំងអស់នោះគឺចាប់ពីការរៀបចំសិក្សាឋានលេខាហូតដល់ការបញ្ចប់ការតាមដានត្រួតពិនិត្យ និងការសាងសង់ (ដំណាក់កាលទី១ ដល់ទី៦ ខាងលើ) អាចត្រូវបញ្ចប់ពេញលេញក្នុងរយៈពេលអនុវត្តរហូតបញ្ចប់១០០%។ ចំណុចលម្អិតនៃសកម្មភាពពេញលេញសម្រាប់ដំណើរការបញ្ចប់ទាំងស្រុងនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធមូលនិធិអភិវឌ្ឍន៍ឃុំ គឺចាប់ផ្តើមពីការកំណត់ ការជ្រើសរើស ការរៀបចំ និងការអនុវត្តត្រូវបានសង្ខេបដូចខាងលើ។

*(ការងារសាងសង់ត្រូវបានធានាដោយអ្នកទទួលការក្នុងរយៈពេល៦ខែបន្ទាប់ ប៉ុន្តែការតាមដានជាក់ស្តែង គឺជាការទទួលខុសត្រូវរបស់មន្ត្រីគាំទ្របច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធនៃទីចាត់ការផែនការ និងវិនិយោគខេត្ត មិនមែនអ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) ឡើយ ប៉ុន្តែ TSC ត្រូវទទួលខុសត្រូវជួយឃុំក្នុងការវាយតម្លៃបញ្ចប់កិច្ចសន្យាបញ្ចប់ការធានា ៦ខែ និងរៀបចំរបាយការណ៍បញ្ចប់ក្នុងករណីមានការស្នើសុំពីឃុំ)។*

## ៥. ការចាត់ចែងកិច្ចសន្យា

ក) កិច្ចសន្យាសេវាបច្ចេកទេសនេះ ត្រូវចុះហត្ថលេខាដោយពីរភាគី ៖ ១). អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) និង ២). លេខាធិការដ្ឋាន គ.ជ.អ.ប.

ខ) លេខាធិការដ្ឋាន គ.ជ.អ.ប. នឹងចាត់តាំងមន្ត្រីគម្រោងសម្រាប់សម្របសម្រួល ត្រួតពិនិត្យលើកិច្ចសន្យា។ មន្ត្រីគម្រោងនេះ នឹងជួបជាមួយអ្នកផ្តល់សេវាបច្ចេកទេសឯកជននៅពេលមានសំណើ ឬតាមការចាំបាច់ (ប្រចាំខែ)។ ប្រធានក្រុមការងារគម្រោងនៅថ្នាក់ឃុំនីមួយៗ គឺជាអ្នកគ្រប់គ្រងផ្ទាល់អំពីវឌ្ឍនភាពនៃគម្រោងសាងសង់ដែលត្រូវរៀបចំគំនូសប្លង់បច្ចេកទេស ដែលបានរៀបចំដោយអ្នកផ្តល់សេវាបច្ចេកទេសឯកជន។ អ្នកផ្តល់សេវាបច្ចេកទេសឯកជនត្រូវរាយការណ៍ជាប្រចាំខែទៅលេខាធិការដ្ឋាន គ.ជ.អ.ប. និងមន្ត្រីគម្រោង។ ការទូទាត់ត្រូវធ្វើសំណើសុំទូទាត់ទៅលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីសុំការឯកភាព ធ្វើការទូទាត់ដោយយោងលើការបញ្ជាក់ពីការយល់ព្រមលើរបាយការណ៍រីកចម្រើនពីប្រធានគណៈកម្មការគ្រប់គ្រងគម្រោងឃុំនីមួយៗ។

គ) តាមសៀវភៅ PIM ឃុំនីមួយៗធ្វើកិច្ចលទ្ធកម្មដោយផ្តល់កិច្ចសន្យាទៅឱ្យអ្នកទទួលការសាងសង់គម្រោង។ គ្រប់ឃុំត្រូវចាត់តាំងអ្នកផ្តល់សេវាបច្ចេកទេសឯកជនដដែល ឱ្យធ្វើជាអ្នកត្រួតពិនិត្យបច្ចេកទេសរបស់ពួកគាត់ (ដូចបាន

[2] នៅក្នុងកិច្ចសន្យាផ្តល់សេវានៅក្នុងស្រុកមួយ គឺមានកម្រោងនច្រើននៅក្នុងឃុំផ្សេងគ្នា។

ពិព័ណនាក្នុងលក្ខខណ្ឌនៃកិច្ចសន្យារវាងឃុំ និងអ្នកទទួលការសាងសង់[3])។ អ្នកផ្ដល់សេវាបច្ចេកទេសឯកជនត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការគ្រប់គ្រងគម្រោងឃុំ (PMC)។

ឃ) អ្នកផ្ដល់សេវាបច្ចេកទេសឯកជន នឹងសម្របសម្រួលនៅថ្នាក់ឃុំជាមួយក្រុមប្រឹក្សាឃុំ ដែលត្រូវបានចាត់តាំងឱ្យទទួលបន្ទុកការងារនេះ។ ក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការនេះ នឹងរាយការណ៍ប្រចាំខែទៅប្រធានក្រុមសម្របសម្រួលថ្នាក់ស្រុកនិងចូលរួមប្រជុំផងដែរ។

## ៦. លក្ខណៈសម្បត្តិ និងបទពិសោធន៍

ក្នុងពេលដំណើរការការងារ អ្នកផ្ដល់សេវាបច្ចេកទេសឯកជនដែលមកពីផ្នែកឯកជន នឹងមិនរំពឹងថាទទួលបានការណែនាំច្រើនអំពីដំណើរការណែនាំពីការអនុវត្តគម្រោងមូលនិធិឃុំ (PIM) និងសៀវភៅណែនាំបច្ចេកទេសរបស់ គ.ជ.អ.ប. ឡើយ។ ដូច្នេះ ក្នុងកំឡុងពេលចាប់ផ្តើមដំណាក់កាលនីមួយៗនៃការសិក្សាលទ្ធភាពគម្រោង រៀបចំគម្រោង រៀបចំលទ្ធកម្ម និងត្រួតពិនិត្យការងារសាងសង់របស់អ្នកទទួលការ អ្នកផ្ដល់សេវាបច្ចេកទេសឯកជននឹងទទួលបានការគាំទ្រ និងសម្របសម្រួលពីមន្ត្រីគម្រោង និងទីចាត់ការផែនការវិនិយោគនៅថ្នាក់ខេត្តលើដំណើរការដែលត្រូវអនុវត្ត។ ដើម្បីមានលទ្ធភាពធ្វើការងារនេះឱ្យមានប្រសិទ្ធភាព បេក្ខជនត្រូវមានសមត្ថភាព និងបទពិសោធន៍ដូចខាងក្រោម៖

- ✓ យ៉ាងហោចណាស់មានកម្រិតជំនាញ ឬសញ្ញាបត្រវិស្វករ ជាពសាស្ត្រកសិកម្ម សំណង់ស៊ីវិល ឬជំនាញប្រហាក់ប្រហែល
- ✓ មានបទពិសោធន៍យ៉ាងតិច០៣ឆ្នាំក្នុងការសិក្សាវាស់ស្ទង់ ការគ្រោងប្លង់គម្រោង ប៉ាន់ស្មានតម្លៃ ត្រួតពិនិត្យគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ (ជាពិសេសគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ឃុំ) ដូចជា ទំនប់ ប្រឡាយ សំណង់ប្រព័ន្ធជាពសាស្ត្រខ្នាតតូច មធ្យម ឬស្រះ។ល។
- ✓ មានចំណេះដឹងស្ដីពីការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា និងការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម
- ✓ចេះប្រើកុំព្យូទ័រដូចជាកម្មវិធី Word, Excel, AutoCAD និងប្រព័ន្ធអ៊ិនធឺណេត អ៊ីម៉ែល
- ✓ ត្រូវតែស្ថិតនៅ ឬមានឆន្ទៈធ្វើការនៅក្នុងឃុំគោលដៅ
- ✓ មានសម្ភារៈ ឧបករណ៍សិក្សាបច្ចេកទេស និងយានជំនិះសម្រាប់ធ្វើដំណើរបានញឹកញាប់ទៅតាមឃុំគោលដៅ។

[3] ភីម ទម្រង់ទី៥០៖ គំរូកិច្ចសន្យា ប្រការ១